# សារសំខាន់ពាក់ព័ន្ធនឹងទឹកដែលបងប្អូនទទួលទាន

សេចក្តីជូនដំណឹងនេះ មានព័ត៌មានសំខាន់ខ្លាំង អំពីទឹកសម្រាប់បរិភោគរបស់បងប្អូន។ បើចង់បានសេចក្តីជូនដំណឹងនេះជាភាសាអេស្ប៉ាញ សូមទូរស័ព្ទទៅខាងនាយកដ្ឋានធនធានទឹកនិងភ្លើងក្រុងឡុងប៊ិច៖ **562-570-2390**៖

**នាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិច ថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០២៤**

# សេចក្តីជូនដំណឹងអំពីទឹកឆ្អិន

**សូមបងប្អូនដាំទឹកឲ្យពុះជាមុនសិន សឹមទទួលទានវា ឬ សឹមយកវាទៅលាងបន្លែបង្ការ និងចំណីអាហារ ដើម្បីចៀសវាងជំងឺ**

កាលពីថ្ងៃ ពុធ ទី ០៩ ខែ តុលា ឆ្នាំ ២០២៤ ក្បាលបំពង់មេសម្រាប់ផ្គត់ផ្គង់ទឹក នៅលើដងវិថី Orange Avenue និងផ្លូវ Wardlow Road បានបែកធ្លាយ។ អាស្រ័យហេតុនេះ ក្រុមប្រឹក្សាត្រួតពិនិត្យធនធានទឹករដ្ឋ អង្គភាពទឹកសម្រាប់បរិភោគ និងនាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិច សូមណែនាំបងប្អូនប្រជាពលរដ្ឋ នៅតំបន់ដែលរងផលប៉ះពាល់ទាំងអស់ សូមប្រើតែទឹកឆ្អិន ឬទឹកដបសម្រាប់ទទួលទាន និងចម្អិនអាហារ ព្រោះដើម្បីជាការប្រុងប្រយ័ត្នសុវត្ថិភាពផង និងដើម្បីចៀសវាជំងឺចុកពោះ ឬជំងឺពោះវៀនផង។

តំបន់ដែលរងផលប៉ះពាល់ទាំងនោះរួមមាន៖

- **ហ្ស៊ីបកូដ 90805** (ខាងកើតផ្លូវល្បឿនលឿន 710-Fwy)
- **ហ្ស៊ីបកូដ 90806** (នៅចន្លោះផ្លូវ Orange Avenue និងផ្លូវ Cherry Avenue, ខាងជើងផ្លូវ Spring Street– ប៉ះពាល់តែប្រព័ន្ធផ្គត់ផ្គង់ទឹកដែលផ្តល់ជូន ដោយនាយកដ្ឋានធនធានទឹកក្រុងឡុងប៊ិចប៉ុណ្ណោះ)
- **ហ្ស៊ីបកូដ 90807**

យើងខ្ញុំនឹងជូនដំណឹងបងប្អូនបន្ថែមទៀត ក្រោយពេលធ្វើតេស្តរួច បើរកឃើញថាទឹកលែងមានបញ្ហា និងអាចទទួលទានបានវិញដោយសុវត្ថិភាព។ ពេលនោះបងប្អូន នឹងលែងចាំបាច់ដាំទឹកឲ្យឆ្អិន ដើម្បីពិសាដូច្នេះទៀតហើយ។ យើងខ្ញុំកំពុងដុតដៃដុតជើងដោះស្រាយបញ្ហានេះ រហូតលទ្ធផលតេស្តបង្ហាញគ្រប់គ្រាន់ ថាទឹកចាប់ផ្តើមអាចពិសាដូចធម្មតាវិញ។

**ហាមទទួលទានទឹក ដោយមិនបានដាំឆ្អិនជាមុន។**

- សូមដាំទឹករហូតពុះមួយ (១) នាទី (ឲ្យពុះគ្រាក់ៗ)។
- រួចហើយទុកវាឲ្យត្រជាក់ សឹមពិសាវា។
- សូមប្រើទឹកឆ្អិន ឬទឹកដបសម្រាប់ទទួលទាន ដុះធ្មេញ និងលាងបន្លែបង្ការ និងចំណីអាហារ រហូតមានការជូនដំណឹងជាថ្មី។
- ទឹកដែលដាំពុះ អាចសម្លាប់បាក់តេរី និងមេរោគឯទៀតក្នុងទឹក។

**បើបងប្អូនមិនមានលទ្ធភាពដាំទឹកឲ្យពុះបានទេ៖**

សូមប្រើទឹកអូសាវ៉ែលដែលគ្មានក្លិន៖

១) សម្រាប់ទឹកថ្លា សូមប្រើទឹកអូសាវ៉ែល ៨ ដំណក់ (១/៨ ស្លាបព្រាកាហ្វេ សម្រាប់ទឹកមួយហ្គាឡុង។ បើទឹកនោះល្អក់ ឬកករ សូមយកក្រណាត់ស្អាតច្រោះវា រួចហើយដាក់ទឹកអូសាវ៉ែល ១៦ ដំណក់ (១/៤ ស្លាបព្រាកាហ្វេ) សម្រាប់ទឹក ១ ហ្គាឡុង។

២) រួចហើយកូរវាឲ្យសព្វ។ ទុកវាចោល ៣០ នាទីសិន សឹមប្រើវា។

៣) ទឹកនោះនឹងមានរស ឬធុំក្លិនដូចក្លរីន។ នេះមានន័យថាមេរោគក្នុងទឹក ត្រូវបានសម្លាប់ហើយ។

ថ្នាំគ្រាប់សម្លាប់មេរោគក្នុងទឹក៖

- សូមធ្វើតាមការណែនាំរបស់ក្រុមហ៊ុនផលិតថ្នាំនោះ។

ទឹកឆៅ បងប្អូននៅតែអាចប្រើប្រាស់បានដែរ ប៉ុន្តែសម្រាប់តែ៖

- ងូតទឹក លាងចាន បោកគក់សម្លៀកបំពាក់ និងស្រោចដំណាំ។

---

**សម្រាប់ព័ត៌មានបន្ថែម**

បើបងប្អូនមានបញ្ហាសុខភាពខ្លួនឯងផ្ទាល់ ឬសុខភាពសមាជិកគ្រួសារបងប្អូនណាម្នាក់ សូមទាក់ទងទៅខាងផ្នែកផ្តល់សេវាថែទាំសុខភាពរបស់បងប្អូន ឬ**នាយកដ្ឋានសុខាភិបាល និងសេវាពលរដ្ឋក្រុងឡុងប៊ិច** តាមលេខនេះ៖ **562-570-4000**។

**លេខទំនាក់ទំនងនាយកដ្ឋានធនធានទឹក៖** 562-570-2390

**ការិយាល័យប្រចាំសង្កាត់នៃក្រុមប្រឹក្សាត្រួតពិនិត្យធនធានទឹករបស់រដ្ឋ៖** 818-551-2004

សូមបងប្អូនចែករំលែកបន្ត ឬផ្សព្វផ្សាយព័ត៌មាននេះ ជាមួយបងប្អូនដែលពិសាទឹកនេះ ជាពិសេសបងប្អូនដែលមិនបានទទួលសេចក្តីជូនដំណឹងនេះដោយផ្ទាល់ (ឧទាហរណ៍ បងប្អូនប្រជាពលរដ្ឋនៅតាមផ្ទះជួល មណ្ឌលថែទាំមនុស្សចាស់ សាលារៀន និងអាជីវកម្ម)។ បងប្អូនក៏អាចជួយបាន ដោយបិទផ្សាយព័ត៌មាននេះ នៅតាមទីសាធារណៈ ឬចែកចាយវាដោយផ្ទាល់ដៃ ឬតាមសំបុត្រប្រៃសនីយ៍។